**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

## បេសកកម្មលើកទីពីររបស់លោក យ៉ាសហ៊ី ហ្គាយ
## តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា
## ថ្ងៃទី១៩-២៨ ខែមីនា ឆ្នាំ២០០៦

*ភ្នំពេញ ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៦* -- លោក **យ៉ាសហ៊ី ហ្គាយ** តំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ចប់ទស្សនៈកិច្ចលើកទីពីររបស់លោក ក្នុងនាមជាតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិនៅថ្ងៃនេះ ។ គោលបំណងចម្បងនៃបេសកកម្មនេះ គឺដើម្បីពិភាក្សាអំពីរបាយការណ៍ និងអនុសាសន៍ដាក់ជូនអង្គការសហប្រជាជាតិ ដែលរបាយការណ៍នេះត្រូវបានពិនិត្យចប់សព្វគ្រប់នៅដើមខែមករា ឆ្នាំ២០០៦ និងដើម្បីស្វែងយល់បន្ថែមទៀតអំពីសភាពការណ៍នេះ ។

លោកតំណាងពិសេសបានជួបជាមួយអង្គការផ្សេងៗជាច្រើននៃសង្គមកម្ពុជា ដែលរួមទាំងរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា មេដឹកនាំនានានៃគណបក្សសមរង្ស៊ី និងគណបក្សហ៊្វុនស៊ិនប៉ិច សមាជិកមួយចំនួននៃក្រុមប្រឹក្សាធម្មនុញ្ញ និងតុលាការ តំណាងអង្គការសិទ្ធិមនុស្ស អង្គការជំនួយផ្នែកច្បាប់ និងសហជីពកម្មករ ក្រុមអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ទ្វេរភាគី និងពហុភាគី និងសហគមន៍អ្នកការទូត ។ លោកបានអញ្ជើញទៅទស្សនៈកិច្ចនៅខេត្តកំពង់ស្ពឺ ដែលនៅទីនោះលោកបានជួបជាមួយជនរងគ្រោះដោយសារជំលោះដីធ្លី និងការបណ្តេញចេញពីដីធ្លី លោកក៏បានអញ្ជើញទៅទស្សនៈកិច្ចនៅខេត្តបាត់ដំបង ដែលនៅទីនោះលោកបានជួបពិភាក្សាជាមួយអភិបាលខេត្ត ប្រធានតុលាការ និង ប្រធានអយ្យការតុលាការខេត្ត និងអង្គការក្រៅរដ្ឋាភិបាលនានា ។

លោកតំណាងពិសេសបានស្វាគមន៍ការដោះលែងឱ្យមានសេរីភាពវិញនូវឥស្សរជនសាធារណៈមួយចំនួនដែលបានរិះគន់ដល់រដ្ឋាភិបាល និងការវិលត្រលប់ចូលស្រុកវិញរបស់លោកសមរង្ស៊ី ។ ទោះជាយ៉ាងណា

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១០ ផ្លូវលេខ ៣០២ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

ក៏ដោយ លោកតំណាងពិសេសបានសំគាល់ឃើញមានបញ្ហាភាគច្រើន ដែលបានសរសេរនៅក្នុងរបាយការណ៍របស់លោកនៅមិនទាន់បានដោះស្រាយនៅឡើយ ហើយលោកសង្ឃឹមថា បរិយាកាសធូរស្រាលជាងនេះ នឹងបង្ហាញឱ្យឃើញពីឱកាសសំរាប់ការផ្លាស់ប្តូរពិតប្រាកដ និងជាវិជ្ជមាន ។ លោកតំណាងពិសេសបានគូសបញ្ជាក់ថា ការសាកល្បងពិតប្រាកដនៃការប្តេជ្ញាចិត្តធ្វើកំណែទម្រង់របស់រដ្ឋាភិបាលនោះ គឺការចាត់វិធានការពិតប្រាកដ ដើម្បីប្រែក្លាយការប្រកាសទាំងនេះ ឱ្យទៅជាកែប្រែពិតប្រាកដនិងជាក់ស្តែង ។

លោកក៏បានស្វាគមន៍ផងដែរ ចំពោះការដែលលោកនាយករដ្ឋមន្ត្រីគាំទ្រការលុបចោលការបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌ ប៉ុន្តែលោកបានសំគាល់ឃើញថា សេចក្តីណែនាំរួមរបស់ក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបរិហាកេរ្តិ៍ មិនបានកែប្រែសភាពការណ៍នេះទេ  ពីព្រោះគេនៅតែណែនាំឱ្យអនុវត្តមាត្រា៦៣ នៃច្បាប់អ៊ុនតាក់ ក្នុងករណីដែលអាចបង្កឱ្យមានអស្ថេរភាពដល់សន្តិសុខសាធារណៈ សណ្តាប់ធ្នាប់សង្គម ឬធ្វើឱ្យមានភាពវឹកវរ ចលាចលដល់ស្ថេរភាពនយោបាយ និងសន្តិសុខជាតិ ។ លោកតំណាងពិសេសបានគូសបញ្ជាក់ជាថ្មីនូវអនុសាសន៍របស់លោកថា មាត្រា៦៣ និងបទបញ្ញត្តិដទៃទៀតនៃច្បាប់អ៊ុនតាក់គួរតែលុបចោល ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀតឡើយ  និងមិនត្រូវឱ្យមានបញ្ញត្តិណាមួយចែងថាការបរិហាកេរ្តិ៍ជាបទព្រហ្មទណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌថ្មីឡើយ ។ លោកតំណាងពិសេសមានការព្រួយបារម្ភថា ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និង ការញុះញង់លើជនទាំងឡាយ ដែលនៅពេលថ្មីៗ បានជាប់ពន្ធនាគារ ហើយនិងជនដែលបាននិរទេសខ្លួនចេញពីប្រទេសកម្ពុជានៅតែជាប់ពីបទចោទប្រកាន់ទាំងនោះនៅឡើយ ។ លោកមានការព្រួយបារម្ភទាំងពីរ ទាំងបុគ្គលដែលជាប់ពាក់ព័ន្ធផងដែរ ពីព្រោះសារនេះបានបញ្ជូនទៅសមាជិកដទៃទៀតនៃសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ។

លោកតំណាងពិសេសបានសំដែងនូវការខកចិត្ត ដែលរាជរដ្ឋាភិបាលមិនបានបញ្ចេញឱ្យដឹងនូវព័ត៌មានទាក់ទងនឹងសម្បទាននានានៃធនធានធម្មជាតិរបស់ប្រទេសកម្ពុជា ក្នុងនោះរួមមានសម្បទានរ៉ែ និងតំបន់អភិវឌ្ឍន៍យោធា ហើយថាព័ត៌មានដែលបានផ្តល់ឱ្យពាក់ព័ន្ធនឹងសម្បទានដីគោលដៅសេដ្ឋកិច្ច គឺទទួលបានតែតិចតួចមិនដូចការរំពឹងទុក ។ លោកបានសំគាល់ឃើញថា ការចាប់យកដីធ្លីបានបន្តធ្វើឱ្យសហគមន៍ជនជាតិភាគតិច និងប្រជាពលរដ្ឋក្រីក្រនៅជនបទបាត់បង់ដីធ្លី និងជីវភាពរស់នៅ ។ លោកបានផ្តល់ជាអនុសាសន៍សុំឱ្យ

ផ្អាកទាំងស្រុងជាបណ្តោះអាសន្ននូវការផ្តល់សម្បទាន និងការលក់ដីធ្លីរបស់ជនជាតិដើមភាគតិច ដោយត្រូវរង់ចាំរហូតដល់មានគោលនយោបាយមួយច្បាស់លាស់ ដើម្បីធានាការពារសិទ្ធិរបស់ជនជាតិដើមភាគតិច ហើយនិងរង់ចាំច្បាប់ពាក់ព័ន្ធចាំបាច់ទាំងអស់ត្រូវបានអនុម័ត និងចូលជាធរមានជាមុនសិន ។ ពាក់ព័ន្ធនឹងអាជ្ញាធរជាតិថ្មីដើម្បីដោះស្រាយទំនាស់ដីធ្លី លោកមានការព្រួយបារម្ភថា វាមានលក្ខណៈដូចជាស្ថាប័នធ្វើគោលនយោបាយច្រើនជាងស្ថាប័នមួយឯករាជ្យដែលមានតួនាទីពិនិត្យភស្តុតាង និងធ្វើការដោះស្រាយតាមវិធីមួយដែលអាចជឿទុកចិត្តបាន និងមានប្រសិទ្ធិភាព ។ លោកក៏មានការព្រួយបារម្ភផងដែរថា អាជ្ញាធរថ្មីនេះអាចនឹងធ្វើឱ្យខូចដល់ប្រព័ន្ធដែលមានស្រាប់នៃគណៈកម្មការសុរិយោដី ដែលកំពុងត្រូវការយ៉ាងខ្លាំងក្នុងការពង្រឹងបន្ថែមទៀត ។ លោកបានពិចារណាថា អង្គការក្រៅរដ្ឋាភិបាលនានា បានធ្វើការសំរេចចិត្តយ៉ាងត្រឹមត្រូវ ដើម្បីធ្វើការជាមួយអាជ្ញាធរនេះពីខាងក្រៅ ស្របទៅតាមតួនាទីភារកិច្ចរបស់ខ្លួនក្នុងសង្គម ។

លោកតំណាងពិសេសមានការព្រួយបារម្ភជាពិសេស អំពីការដែលនៅតែបន្តមានការជ្រៀតជ្រែកពីសំណាក់ស្ថាប័ននីតិប្រតិបត្តិទៅក្នុងកិច្ចការតុលាការ ឧទាហរណ៍តាមរយៈគោលនយោបាយ "កណ្តាប់ដៃដែក" និងអំពីការដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនអាចអនុវត្តតួនាទីដ៏សំខាន់របស់ខ្លួនបាន ក្នុងការធានាការពារសេចក្តីសុច្ចរិត និងឯករាជ្យភាពនៃតុលាការ ។ វាជាការសំខាន់ខ្លាំងណាស់ ដែលគេត្រូវតែពង្រឹងក្រុមប្រឹក្សានេះ តាមរយៈការធានាឯករាជ្យភាព និងសុច្ចរិតភាពរបស់ខ្លួន ។ លោកបានកត់សំគាល់ថា និទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបានចាក់ឫសយ៉ាងជ្រៅនៅក្នុងប្រទេសកម្ពុជា ហើយថាគេមិនអាចដោះស្រាយបញ្ហានេះបានទេ ប្រសិនបើគ្មានស្ថាប័នតុលាការមួយឯករាជ្យ មានសមត្ថភាព និងមិនលំអៀងនោះ ។ លោកតំណាងពិសេសយល់ឃើញថា លក្ខខណ្ឌជាគន្លឹះសំរាប់ការធានាការពារឯករាជ្យភាពនៃតុលាការគឺថា ស្ថាប័ននីតិប្រតិបត្តិត្រូវមានឆន្ទៈពិតប្រាកដ ក្នុងការបញ្ឈប់ការជ្រៀតជ្រែកចូលក្នុងកិច្ចការតុលាការ ។ ចៅក្រមក៏ត្រូវតែមានច្បាប់មួយរឹងមាំសំរាប់គ្រប់គ្រងលើឋានៈរបស់ខ្លួនដែរ ។

លោកតំណាងពិសេសបានសំដែងការព្រួយបារម្ភថា ស្របគ្នាជាមួយនឹងការពិភាក្សាអំពីភាពបើកចំហថ្មីមួយ ការងារព្រាង និងអនុម័តច្បាប់កំពុងដំណើរការដែលអាចកំណត់ពីសេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការប្រជុំ ។ ច្បាប់ទាំងនេះ ប្រសិនបើចាំបាច់ត្រូវតែមាន គេគួរតែកំណត់ពីលក្ខខណ្ឌដើម្បីឱ្យ

អង្គការនានាអាចអនុវត្តន៍ការងាររបស់ខ្លួន និងដើម្បីឱ្យប្រជាពលរដ្ឋអាចរួមប្រជុំ និងសំដែងមតិរបស់ខ្លួនបានដោយសេរី និងដោយសន្តិវិធី ។

លោកតំណាងពិសេសបានធ្វើសេចក្តីសន្និដ្ឋានថា បញ្ហាទាំងឡាយដែលបានពិភាក្សានៅក្នុងរបាយការណ៍របស់លោកនៅតែមានសុពលភាព និងមានភាពបន្ទាន់ជាដដែល ។ លោកក៏បានគូសបញ្ជាក់ថា ការទទួលខុសត្រូវ និងតួនាទីរបស់រដ្ឋាភិបាល និងទីភ្នាក់ងារនានាក្នុងផ្តល់ជំនួយអភិវឌ្ឍន៍ដល់ប្រទេសកម្ពុជា ដើម្បីជួយ ឱ្យប្រទេសកម្ពុជាបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលប្រទេសនេះជាប់កាតព្វកិច្ចត្រូវអនុវត្តតាម និងជំរុញឱ្យមានកំណែទម្រង់ស្របទៅតាមបទដ្ឋាន និងការធានាទាំងឡាយដែលមានចែងនៅក្នុងសន្ធិសញ្ញាទាំងនេះ ។

លោកតំណាងពិសេសនឹងចេញរបាយការណ៍ខ្លីមួយ ដើម្បីធ្វើបច្ចុប្បន្នភាពទៅលើរបាយការណ៍របស់លោកនៅដើមខែឧសភាខាងមុខនេះ ។